ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ២២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ដោយអនុលោមទៅតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

**មាត្រា ២.–**

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ជាស្ថាប័នចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា ៣.–**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ជាសេនាធិការផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ មានសិទ្ធិពេញលេញ សេរីភាពគ្រប់គ្រាន់ គ្មានការហាមប្រាម គ្មានការរារាំងក្នុងការពិនិត្យឡើងវិញលើបញ្ជីកត់ត្រា ចំណូលចំណាយថវិកា ទ្រព្យសម្បត្តិ និងបញ្ជីបុគ្គលិករបស់អង្គភាពទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ។

**មាត្រា ៤.–**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ មានភារកិច្ចសំខាន់ៗដូចតទៅ:

- ធ្វើផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំឱ្យមានភាពសមស្របច្បាស់លាស់គ្រប់គ្រាន់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យ និងសម្រេច។
- ពិនិត្យឡើងវិញលើការអនុវត្តច្បាប់ បទបញ្ជា វិន័យថវិកា និងអភិបាលកិច្ចល្អនៅក្នុងប្រតិបត្តិការ ហិរញ្ញវត្ថុពិសេសការកៀរគរ និងគ្រប់គ្រងចំណូល ការចំណាយ ថវិកាហិរញ្ញប្បទាន និងបំណុល។
- ធ្វើការវាយតម្លៃផែនការ និងសកម្មភាពសវនកម្មផ្ទៃក្នុង ដែលបានចាត់ចែងកន្លងមក។
- ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃសវនកម្មផ្ទៃក្នុងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ។
- ពិនិត្យឡើងវិញលើគ្រប់ព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការនានា ដើម្បីធានាភាពច្បាស់លាស់ជឿទុកចិត្ត និងទាន់ពេលវេលា។
- ពិនិត្យឡើងវិញលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិដែលបានបង្កើត ដើម្បីធានាលើកិច្ចប្រតិបត្តិការឱ្យមានប្រសិទ្ធភាព។
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឱ្យបានត្រឹមត្រូវ។

- ពិនិត្យឡើងវិញលើកម្មវិធីនៃកិច្ចប្រតិបត្តិការគម្រោងចំណាយមូលធនដើម្បីធានាបានតាមគោលបំណង និងផែនការដែលបានដាក់ចុះ ។
- ពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងភាពសន្សំសំចៃ ដើម្បីមានវិធានការកែលម្អ ។
- សម្របសម្រួលការងារ និងសហប្រតិបត្តិការជាមួយអគ្គាធិការដ្ឋាន អាជ្ញាធរសវនកម្មជាតិ និងស្ថាប័នពាក់ព័ន្ធ ។
- ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវរាយការណ៍ដោយផ្ទាល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។
- បំពេញកិច្ចការផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា ៥.–**

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ដឹកនាំ និងគ្រប់គ្រងដោយប្រធាន ០១រូប និងអនុប្រធាន ០១ ចំនួនតាមការចាំបាច់ ។
- ចំនួនការិយាល័យនានាចំណុះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកកំណត់ ។
- ប្រធាន អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាន និងអនុប្រធានការិយាល័យចំណុះត្រូវតែជាមន្ត្រីក្នុងក្របខណ្ឌ ហើយមានសញ្ញាប័ត្រចាប់ពីថ្នាក់ឧត្តមសិក្សា ឬសញ្ញាប័ត្រសមមូលផ្នែកគណនេយ្យ ឬពាណិជ្ជកម្ម និងហិរញ្ញវត្ថុ មានបទពិសោធន៍ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ឬ គ្រប់គ្រងរដ្ឋបាលសាធារណៈយ៉ាងតិច ៥ឆ្នាំឡើងទៅ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៦.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី “ដើម្បីជូនជ្រាប”
- ដូចមាត្រា ៧ “ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ